ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៥៩ ដែលមានទុនវិនិយោគសរុបប្រមាណ៨១៦លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងខែឧសភា ឆ្នាំ២០២៥

ក្នុងខែឧសភា ឆ្នាំ២០២៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន**៥៩គម្រោង** ដែលមានទុនវិនិយោគសរុបប្រមាណ**៨១៦លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**៤៤ពាន់កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន៣៨គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន២១គម្រោង។ ក្នុងខែឧសភា ឆ្នាំ២០២៥នេះ ការចុះបញ្ជីគម្រោងវិនិយោគមានការកើនឡើងចំនួន ៣៤ គម្រោង ស្មើនឹងប្រមាណ ១៣៦% ខណៈទុនវិនិយោគមានការកើនឡើងប្រមាណ ៥៧០លានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ ២៣១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។

គិតចាប់ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២៥ ការចុះបញ្ជីគម្រោងវិនិយោគមានចំនួន ២៩០គម្រោង កើនឡើងចំនួន១៣៧គម្រោង ស្មើនឹងប្រមាណ៩០% ខណៈទុនវិនិយោគមានចំនួនប្រមាណ ៤,២៣ពាន់លានដុល្លារអាម៉េរិក កើនឡើងប្រមាណ ១,៤៣ពាន់លានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ៥២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។

ជាការកត់សម្គាល់ គម្រោងវិនិយោគដែលមានភាពលេចធ្លោជាងគេប្រចាំខែឧសភានេះ រួមមាន៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ | **គម្រោងអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព ១៥០មេហ្គាវ៉ាត់** |
| | -ទីតាំង៖ ស្រុកអូររាំង ខេត្តមណ្ឌលគិរី |
| | -ទុនវិនិយោគ៖ ប្រមាណ២០៧លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ១៤៤កន្លែង។ |

### ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងពង្រីកផលិតកម្មផលិតសំបកកង់រថយន្ត** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ស៊ីន បារិត ខេត្តស្វាយរៀង |
| | -ទុនវិនិយោគបន្ថែម៖ ប្រមាណ២៤៤លានដុល្លារអាម៉េរិក។ |
| | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតសារធាតុគីមីសម្រាប់វិស័យឧស្សាហកម្ម** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ហ័រស៊ាំង អ៊ិនធើណេសិនណាល ខេត្តស្វាយរៀង |
| | -ទុនវិនិយោគ៖ ប្រមាណ២០លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ៤៦១កន្លែង។ |

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែឧសភា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៥៩** (២១ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៨១៦** លាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៤៤ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)

**២៣៧លាន**
វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ



**៥៧៩លាន**
វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៨៤,៨០% |
| ២. កម្ពុជា | ៨,៩០% |
| ៣. សិង្ហបុរី | ៣,៤៥% |
| ៤. កោះ Samoa | ១,៧៨% |
| ៥. សាធារណរដ្ឋកូរ៉េ | ១,០៧% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ១១+
- ៦-១០
- ១-៥
- មិនមាន

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុងរយៈពេល ៩ខែ ឆ្នាំ២០២៤

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**២៩០** (១២១ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៤,២** ប៊ីលាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~២០០ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)

**៥៥៨លាន** វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**២០លាន** វិស័យទេសចរណ៍



**៣,៦ប៊ីលាន** វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៦២,២៧% |
| ២. កម្ពុជា | ២៣,២៨% |
| ៣. សិង្ហបុរី | ៩,៦៣% |
| ៤. កោះ British Virgin | ១,៤៤% |
| ៥. វៀតណាម | ០,៩៩% |
| ៦. អង់គ្លេស | ០,៦៧% |
| ៧. កោះ Cayman | ០,៥៩% |
| ៨. កោះ Samoa | ០,៤៧% |
| ៩. សាធារណរដ្ឋកូរ៉េ | ០,២១% |
| ១០. សហរដ្ឋអាមេរិក | ០,១៥% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ៣១+
- ២១-៣០
- ១១-២០
- ១-១០
- មិនមាន